ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

**សុន្ទរកថា**
**ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះ**
នៅខេត្តក្រចេះ ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩

សូមគោរព :

- ឯកឧត្តម នូ ភឿង ប្រធានក្រុមប្រឹក្សាខេត្តក្រចេះ និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវអគារសាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះ នៅភាគឦសាននៃប្រទេសកម្ពុជា បន្ទាប់ពីយើងបានរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអបអរសាទរចំពោះសមិទ្ធផលនានា ដែលវិស័យធនាគារបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្នុងរយៈពេល ៣០ឆ្នាំ ក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ លើរបបប្រល័យពូជសាសន៍មក ។ អគារទីស្នាក់ការនេះគឺជាសមិទ្ធផលថ្មីមួយបន្ថែមទៀត ដែលវិស័យធនាគារបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមជារូបវ័ន្តជូនជាតិមាតុភូមិ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម នូ ភឿង** ប្រធានក្រុមប្រឹក្សាខេត្តក្រចេះ **ឯកឧត្តម ធុន ត្រី** អភិបាលរងខេត្តក្រចេះ តំណាងមន្ទីរ-អង្គភាព និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានផ្តល់ កិច្ចសហប្រតិបត្តិការល្អ ក្នុងការរៀបចំសាងសង់អគារធនាគារនេះ និងបង្កបរិយាកាសល្អឱ្យគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។ ស្មារតីកិច្ចសហប្រតិបត្តិការនេះ គឺជាកត្តាស្នូលធ្វើឱ្យការងារ របស់យើងបានទទួលជោគជ័យ ។ តាមរបាយការណ៍របស់ លោក ចាន់ មុនី នាយកសាខាធនាគារជាតិនៃកម្ពុជា ខេត្តក្រចេះ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះនេះ ត្រូវបានសាងសង់ឡើងស្របតាមកម្រិតស្តង់ដារអន្តរជាតិ ដោយគ្រប់បន្ទប់បំពាក់ដោយប្រព័ន្ធកុំព្យូទ័រ ទាំងផ្នែកខាងក្នុង និងខាងក្រៅបំពាក់ដោយប្រព័ន្ធការពារសុវត្ថិភាពទំនើប ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា !

ឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបថា ប្រព័ន្ធធនាគារនៅកម្ពុជា មានធនាគារជាតិនៃកម្ពុជា ដែលមានសាខានៅទូទាំងប្រទេស គឺជាអាជ្ញាធររូបិយវត្ថុជាតិ និងជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកំពុងធ្វើប្រតិបត្តិការនៅប្រទេសកម្ពុជា ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាលដែលបានធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងតូបប្តូរប្រាក់ជាដើម ។ ប្រព័ន្ធធនាគារបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច តាមការគៀងគរប្រាក់សញ្ញើដែលនៅទំនេរឱ្យចូលក្នុងប្រព័ន្ធ ហើយយកទៅផ្តល់ឥណទានសម្រាប់ពង្រីកគម្រោងវិនិយោគនានា ។

ធម្មតាអត្រាការប្រាក់ឥណទាន តែងតែមានកម្រិតខ្ពស់ ដោយសារទុនដែលយើងបានទទួលមកនោះ មានតម្លៃការប្រាក់ និងថ្លៃចំណាយប្រតិបត្តិការរបស់ខ្លួនមួយរួចទៅហើយ។ ដូច្នេះ ការផ្តល់ឥណទាននេះ ប្រៀបបាននឹងការរកស៊ីចិញ្ចឹមគ្នាទៅវិញទៅមក ។ ដើម្បីបង្កលក្ខណៈឱ្យអត្រាការប្រាក់ឥណទានថយចុះក្នុងកម្រិតមួយសមស្របថែមទៀត រាជរដ្ឋាភិបាលបានកំពុងនិងខិតខំកសាងហេដ្ឋារចនាសម្ព័នសង្គមជារូបវ័ន្ត ដូចជាផ្លូវគមនាគមន៍ខ្វាត់ខ្វែងរហូតដល់ជនបទ ដើម្បីធ្វើឱ្យប្រជាជនរបស់យើងនៅទូទាំងប្រទេស និងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ មានលទ្ធភាពងាយស្រួលកាន់តែច្រើនក្នុងការទំនាក់ទំនង និងធ្វើប្រតិបត្តិការ ។

ចំណែកឯការធ្វើទំនើបកម្មសាខាធនាគារជាតិនៃកម្ពុជា គឺឆ្លើយតបទៅនិងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ក្នុងកម្មវិធីកំណែទម្រង់នេះ រាជរដ្ឋាភិបាលតម្រូវឱ្យគណនីរបស់ស្ថាប័នរដ្ឋស្ទើរតែទាំងអស់ ដែលបានបើកនៅធនាគារពាណិជ្ជ ត្រូវផ្ទេរមកបើកនិងធ្វើប្រតិបត្តិការ តាមរយៈធនាគារជាតិនៃកម្ពុជាវិញ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ សម្រាប់បើកប្រាក់បៀវត្សជូនដល់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធទូទាំងប្រទេស និងទទួលការបង់ចំណូលប្រាក់ពន្ធគ្រប់ប្រភេទ ។ មូលហេតុនេះ ទើបធនាគារជាតិនៃកម្ពុជា បានប្រកាសបើកសាខាផ្លូវការរបស់ខ្លួននៅទូទាំងប្រទេស ក្នុងនោះក៏មានសាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះមួយផងដែរ ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់របស់ទីផ្សារ និងការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិយើងបច្ចុប្បន្ននេះ ។

ការជ្រើសរើសខេត្តក្រចេះ ធ្វើជាទីតាំងអាទិភាពសម្រាប់ធ្វើទំនើបកម្មបណ្តាញសេវា និងប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជានេះ ដោយយល់ឃើញថា ខេត្តក្រចេះស្ថិតនៅភាគឦសាន ជាប់នឹងដងទន្លេមេគង្គមានសក្តានុពលសេដ្ឋកិច្ច ទាំងផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម សិប្បកម្មកែច្នៃផលិតផលកសិកម្មតូចនិងមធ្យម ផ្នែកទេសចរណ៍ គឺជាតំបន់អេកូទេសចរណ៍ មានរមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងមានសំណង់អគារបូរាណតាមបែបស្ថាបត្យកម្មបារាំង និងផ្នែកពាណិជ្ជកម្ម គឺជាតំបន់ដែលមានព្រំប្រទល់ជាប់នឹងទល់ដែនប្រទេសវៀតណាម មានលក្ខណៈងាយស្រួលក្នុងកាដោះដូរពាណិជ្ជកម្មឆ្លងដែន ។

គោលបំណងសំខាន់នៃការកែលម្អធ្វើទំនើបកម្មទីស្នាក់ការថ្មីនេះ គឺដើម្បី *ទី១)* - ពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ *ទី២)* -គាំទ្រ ការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និង *ទី៣)* -គឺអនុវត្តមុខងារ និងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ជាអាជ្ញាធររូបិយវត្ថុផង ជាធនាគារិករបស់ធនាគារផង និងជាអាជ្ញាធរ អាណាព្យាបាលលើប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុទាំងមូលផង ។ ទាំងនេះ គឺជាយន្តការដើម្បីពង្រឹងជំនឿទុកចិត្ត របស់សាធារណជនមកលើប្រព័ន្ធធនាគារ និងការប្រើប្រាស់ប្រាក់រៀល និងរក្សាស្ថិរភាពថ្លៃ ឆ្ពោះទៅរួមចំណែក ពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ។

ក្នុងមុខងារជា **អាជ្ញាធររូបិយវត្ថុ** សាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះ នឹងដើរតួនាទីជាអ្នកផ្គត់ផ្គង់ និងត្រួតពិនិត្យសាច់ប្រាក់ និងជាអ្នកសម្របសម្រួលចរាចររូបិយវត្ថុឱ្យរតនាគារខេត្ត ធនាគារពាណិជ្ជ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងអង្គការឬក្រុមហ៊ុន និងសាធារណជននានា សំដៅរក្សាស្ថិរភាពតម្លៃប្រាក់រៀល និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលបន្ថែមទៀត ឆ្ពោះទៅរកការអនុវត្តកម្មវិធីពង្រឹងអន្តរការិយកម្មធនាគារ និងទីផ្សារហិរញ្ញវត្ថុនៅពេលអនាគត ។

ក្នុងមុខងារជា **ធនាគាររបស់រដ្ឋាភិបាល** និង **ជាធនាគាររបស់ធនាគារ** សាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះ នឹងទទួលបើកគណនីគ្រប់ប្រភេទឱ្យមន្ទីរ-អង្គភាពរដ្ឋ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីសម្រួលក្នុងការធ្វើចរាចរសាច់ប្រាក់ និងបម្រើសេវាជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ចាប់ពីថ្ងៃនេះតទៅ សាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះ :

ទី១/- នឹងក្លាយទៅជាកន្លែងសម្រាប់ទទួលការបង់ពន្ធគ្រប់ប្រភេទ និងជួយសម្រួលដល់កិច្ចប្រតិបត្តិការសេវាធនាគារផ្សេងៗ ជូនមន្ទីរ-អង្គភាព និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានានៅទូទាំងខេត្តក្រចេះ ។

ទី២/-នឹងជួយសម្រួលដល់សកម្មភាពពាណិជ្ជកម្ម ជាអ្នកផ្គត់ផ្គង់និងត្រួតពិនិត្យសាច់ប្រាក់ និងជាអ្នកសម្របសម្រួលចរាចររូបិយវត្ថុឱ្យរតនាគារខេត្ត ធនាគារពាណិជ្ជ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងអង្គការ ឬក្រុមហ៊ុន និងសាធារណជននានា ។

ទី៣/- បង្កលក្ខណៈងាយស្រួលឱ្យបងប្អូនប្រជាពលរដ្ឋទូទៅ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករសេដ្ឋកិច្ចផ្សេងទៀត មកប្តូរក្រដាសប្រាក់រហែក ទក់ ខូចគុណភាព ដើម្បីយកក្រដាសប្រាក់ថ្មីមកប្រើប្រាស់តាមតម្រូវការ ។

ទី៤/- អគារថ្មីនេះ គឺជាសញ្ញាបញ្ជាក់ថា វិស័យធនាគារនៅកម្ពុជាមានភាពរឹងមាំ មានហេដ្ឋារចនាសម្ព័ន្ធដល់ខេត្ត-ក្រុង និងបានជួយរួមចំណែកកែប្រែជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់ឥណទានពីប្រព័ន្ធធនាគារ យកទៅប្រើប្រាស់ ។

ទី៥/- អគារថ្មីនេះ មិនត្រឹមតែជាសមិទ្ធផល និងជាទ្រព្យសាធារណៈរបស់រដ្ឋប៉ុណ្ណោះទេ តែថែមទាំងបានជួយលើកសោភ័ណ្ឌភាពដល់ខេត្តក្រចេះទៀតផង ជាពិសេស អគារនេះនឹងធ្វើជាឃ្លាំងប្រាក់សម្រាប់ផ្ទុកទ្រព្យសម្បត្តិរដ្ឋឱ្យមានសុវត្ថិភាពប្រចាំតំបន់នេះ និង

ទី៦/- ជាទិសដៅ គឺបន្តជម្រុញអភិវឌ្ឍសេវាកម្មធនាគារនិងហិរញ្ញវត្ថុឱ្យកាន់តែសម្បូរបែប កាន់តែមានការប្រកួតប្រជែងដោយស្មើភាពនិងផលិតភាពថែមទៀត ហើយប្រជាជនកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មធនាគារសម្រាប់បង្កើនជីវភាពប្រចាំថ្ងៃរបស់ខ្លួនកាន់តែប្រសើរឡើង ។

ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !

សរុបមក សមិទ្ធផលនេះ កើតឡើងដោយសារមានការចូលរួមសហការល្អ ពីអាជ្ញាធរមានសមត្ថកិច្ចប្រចាំដែនដីគ្រប់លំដាប់ថ្នាក់ និងបងប្អូនប្រជាជនទាំងអស់ ហេតុដូច្នេះហើយ ទើបយើងចាត់ទុកសមិទ្ធផលនេះ គឺជាមោទនភាពរួមគ្នារបស់ធនាគារជាតិនៃកម្ពុជា អាជ្ញាធរដែនដី និងប្រជាជនក្នុងខេត្តក្រចេះទាំងមូលផងដែរ ។ សមិទ្ធផលថ្មីនេះ ត្រូវបានកសាងឡើងឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ទីផ្សារ និងចូលរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំនៅតែមានជំនឿយ៉ាងមុតមាំថា ឯកឧត្ដម លោក លោកស្រី នាងកញ្ញា ជាតំណាងអាជ្ញាធរដែនដី មន្ទីរអង្គភាពនៅជុំវិញខេត្តទាំងអស់ និងប្រជាជននៅទូទាំងខេត្តក្រចេះ នៅតែបន្តស្មារតីសហការសាមគ្គីជាប្រពៃណីទាំងកម្លាំងកាយ និងកម្លាំងចិត្តបន្តទៀត ។ ស្មារតីសាមគ្គីនេះហើយ គឺជាកត្តាមួយសំខាន់បំផុតក្នុងការកំណត់ជ័យជំនះគ្រប់វិស័យ ។

មុននឹងបញ្ចប់នេះ ឆ្លៀតឱកាសមុនថ្ងៃបុណ្យចូលឆ្នាំសកល ឆ្នាំ២០១០ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី នាងកញ្ញា សូមមានសុខភាពល្អ មានជ័យជំនះគ្រប់ភារកិច្ច និងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើក "**សាខាធនាគារជាតិនៃកម្ពុជាខេត្តក្រចេះ**" ដើម្បីធ្វើជាឃ្លាំងប្រាក់សម្រាប់ផ្ទុកទ្រព្យសម្បត្តិរដ្ឋប្រចាំតំបន់នេះ និងជាសមិទ្ធផលនៃវិស័យធនាគារថ្មីមួយបន្ថែមទៀតសម្រាប់អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងប្រជាជនទូទៅនៅខេត្តក្រចេះទាំងមូល ។ ដូច្នេះ សូមរួមគ្នាជួយថែរក្សា និងប្រើប្រាស់ជាសម្បត្តិសាធារណៈចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**